# លទ្ធផលរបស់អង្គការអភិវឌ្ឍន៍ជីវភាពកសិករ ឆ្នាំ២០២១

## របាយការណ៍សំខាន់ៗរបស់នាយកប្រតិបត្តិ

អង្គការអភិវឌ្ឍន៍ជីវភាពកសិករ (Farmer Livelihood Development Organization)បានដំណើរការអនុវត្តគម្រោងរបស់ខ្លួនចំនួន២នៅក្នុងខេត្តចំនួន២គឺខេត្តពោធិសាត់ និងខេត្តសៀមរាប ដែលគ្របដណ្តប់លើស្រុកចំនួន៣ ឃុំចំនួន០៦ ឬស្មើរនឹង៣៥ ភូមិគោលដៅ។

គម្រោងគម្រោងនៅខេត្តពោធិ៍សាត់បានចាប់ផ្តើមវគ្គទី២ ចាប់ពីខែកក្កដា ដល់ខែមិថុនា ឆ្នាំ២០២២ ចំណែកឯគម្រោងនៅខេត្ត សៀមរាប នឹងបញ្ចប់នៅចុងខែមីនាឆ្នាំ ២០២២។

ក្រុមប្រឹក្សាភិបាលរបស់អេហ្វអិលឌី និងបុគ្គលិកបានជួបប្រជុំគ្នាចំនួន២ដងដើម្បីរៀបចំកែសម្រួលផែនការយុទ្ធសាស្ត្ររបស់អង្គការ និងបង្ហាញទិសដៅក្នុងការសម្រេចផែនការគោលរបស់អេហ្វអិលឌី។ កិច្ចប្រជុំពិសេសផ្សេងទៀតក៏បានប្រព្រឹត្តទៅផងដែរដើម្បីកំណត់នូវរចនាសម្ព័ន្ធព្រមទាំងកែលំអរយុទ្ធសាស្ត្រឲ្យស្របទៅតាមបរិបទ និងការផ្លាស់ប្តូររបស់អេហ្វអិលឌី។

ជោគជ័យដែលមានលើកឡើងនៅទីនេះនឹងមិនអាចមានឡើយប្រសិនបើគ្មានវត្តមាននិងការតម្រង់របស់ក្រុមប្រឹក្សានាយករបស់អេហ្វអិលឌី ព្រមទាំងម្ចាស់ជំនួយនិងអង្គការដៃគូដទៃទៀត និងការចូលរួមសហការពីអាជ្ញាធរក្នុងតំបន់។ ការគាំទ្រការយោគយល់ និងជំបូន្មានរបស់ពួកគាត់បានរុញច្រានឲ្យអេហ្វអិលឌីរួមចំនែកយ៉ាងល្អដល់ក្រុមកសិករព្រមទាំងគ្រួសារដែលក្រីក្ររបស់កម្ពុជា។ ជំនួសមុខឲ្យក្រុមអ្នកទទួលផលរបស់គម្រោង យើងសូមសម្តែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ម្ចាស់ជំនួយ ដៃគូនានា និងស្ថាប័នពាក់ព័ន្ធដែលដូចដែលមានរាយឈ្មោះនៅក្នុងឯកសារបូកសរុបនេះ។

## គោលបំណងៈ

គោលបំណងរបស់អង្គការអភិវឌ្ឍន៍ជីវភាពកសិករ (FLD) គឺអន្តរាគមដើម្បីគ្រួសារក្រីក្រនៅជនបទ(ដែលរួមដោយស្ត្រីកសិករននិងកុមារ) អាចធនាបាននូវការផ្គត់ផ្គង់ប្រាក់ចំនូលនិងស្បៀងអាហារ។ ដើម្បីសម្រេចគោលបំណងនេះ គម្រោងដែលគាំទ្រដោយម្ចាស់ជំនួយបានផ្តោតកិច្ចការរបស់ខ្លួនទៅលើ៖

១. ការបង្កើនសុវត្ថិភាពស្បៀង និងអាហារូបត្ថម្ភ
២. ការកែលម្អសកម្មភាពបង្កើតប្រាក់ចំណូល
៣.ការជួយដល់កសិករនូវឳកាសទទួលបានបច្ចេកទេសកសិកម្ម ព្រមទាំងឳកាសនាំផលរបស់គេទៅកាន់ទីផ្សារ
៤. កម្មវិធីទឹកស្អាត និងអនាម័យនៅក្នុងសហគមន៍
៥. កិច្ចការសម្របសម្រួលទៅតាមអាកាសធាតុដើម្បីនិរន្តរភាពជីវភាព

គម្រោងចំនួន២បានរួមចំណែកក្នុងការសម្រេចគោលបំណងនេះ៖

**គម្រោង៖** គម្រោងសហគមន៍រុងរឿង (Greater Community Project)
**ម្ចាស់ជំនួយ៖** Caritas Australia
**រយៈពេលគម្រោង៖** ១ កក្កដា ២០១៩ ដល់ ៣០ មិថុនា ២០២៤
**តំបន់គោលដៅ៖** ស្រុកបាកាន ខេត្តពោធិសាត់
**គោលបំណងគម្រោង៖** ដើម្បីលើកស្ទួយស្ថានភាពជីវភាពរបស់សមាជិកសហគមន៍តាមរយៈការលើកស្ទួយការយល់ដឹងអំពីអណាម័យដូចជាការលាងដៃ ការប្រើប្រាស់ទឹកស្អាត ការសាងសង់បង្គន់អណាម័យ។ គម្រោងក៏លើកស្ទួយផងដែរនូវសកម្មភាពរកប្រាក់ចំណូលដូចជាសកម្មភាពចិញ្ចឹមសត្វនិងសួនបន្លែ បច្ចេកទេសទំនើបក្នុងផលិតកម្មដំណាំស្រូវ សមាគមមនុស្សចាស់ ក្លឹបកុមារ ព្រមទាំងពង្រឹងសមត្ថភាពថ្នាក់ដឹកនាំភូមិសំដៅកាត់បន្ថយអំពើហឹង្សានិងបង្កើនសាមគ្គីភាព។

## សមិទ្ធិផលគម្រោងសហគមន៍រុងរឿងឆ្នាំ២០២១៖

- គម្រោងសហការជាមួយគណៈកម្មការអភិវឌ្ឍន៍ភូមិបានរៀបចំទិវាសម្អាតសហគមន៍ និងសាលារៀននៅភូមិបត់ត្រាច អូ សាមគ្គី សំរោង និងឬស្សីតាមាន់ និងសាលាបឋមសិក្សាសម្រោងជ័យ អូ និងបត់ត្រាច ដែលមានអ្នកចូលរួមចំនួន ៣៤១នាក់ (ប្រុស ២៩នាក់ ស្រី ៦៩នាក់ កុមារា ១៣៤នាក់ កុមារី ១០៧នាក់ និងបុរសពិការ ០២នាក់)
- គម្រោងបានបើកវគ្គបណ្តុះបណ្តាលស្តីពីអនាម័យខ្លួនប្រាណនិង បរិស្ថានជុំវិញផ្ទះចំនួន ១០វគ្គ សំរាប់៥ភូមិ ដែលមានអ្នកចូលរួមចំនួន ៣១១នាក់មានបុរស ១០២ ស្ត្រី១៧០ ក្មេងប្រុស១៧ ក្មេងស្រី២០ បុរសពិការ ២នាក់ ។គម្រោងបានបណ្តុំបណ្តាលស្តីពីសហគមន៍ដឹកនាំធ្វើអនាម័យចំនួន ៥វគ្គ ដែលមានអ្នកចូលរួមចំនួន ៣១២នាក់ (ប្រុស ៥៤នាក់ ប្រុស ២០៩នាក់ កុមារា ១៦នាក់ កុមារី ៣០នាក់ និងបុរសពិការ ០៣នាក់)។
- គម្រោងបានវគ្គបណ្តុះបណ្តាលស្តីពីការលាងសំអាតដៃជាមួយនិងសាប៊ូចំនួន  ៥វគ្គ សំរាប់៥ភូមិ និង សាលាបឋមសិក្សាចំនួន ០៣ មានអ្នកចូលរួម ១១១៩នាក់ (បុរស៨៤ ស្ត្រី ២៣៨ ក្មេងប្រុស៣៥០ ក្មេងស្រី ៤៤១ បុរសពិការ ០៥ និង ស្ត្រីពិការ ១នាក់ ។ ក្នុងចំណោមអ្នកចូលរួមមាន ៥៥នាក់មកពីគ្រួសារក្រ ១ និងក្រ២។
- គម្រោងបានបណ្តុះបណ្តាលស្តីពីការគ្រប់គ្រង និងដឹកនាំសហគមន៍ដែលមានអ្នកចូលរួមចំនួន ២៥នាក់ (ស្រី ១២) ដែលជាគណៈកម្មការអភិវឌ្ឍន៍ភូមិ និងអ្នកស្ម័គ្រចិត្តសុខភាពភូមិ។
- គម្រោងបានបណ្តុះបណ្តាលគ្រូបង្គោលស្តីពីទឹកស្អាត និងអនាម័យដែលមានអ្នកចូលរួមចំនួន ២៣នាក់ (ស្រី ១២នាក់)
- គម្រោងបានសាងសង់បង្គន់អនាម័យដល់សហគមន៍ចំនួន ៦៨បង្គន់អនាម័យបានសាងសង់រួច សំរាប់៦៨គ្រួសារមានមនុស្ស ៣៥៨នាក់ មានបុរស៩០ ស្ត្រី ១០៤ កុម៉ារា ៦៧ កុម៉ារី  ៩៤ បុរសពិការ ២ និងស្ត្រីពិការ ១នាក់។
- គម្រោងបានផ្តល់សំភារៈអាងស្តុកទឹកភ្លៀងចំនួន ១០១ ឈុត សំរាប់១០១ គ្រួសារ(៥ភូមិ)មានមនុស្ស ៤៨៥នាក់ (បុរស ១២៩នាក់ ស្ត្រី ១៤៦នាក់ កុមារា ៨៩នាក់ កុមារី  ១១៨នាក់ បុរសពិការ ១នាក់ និង ស្ត្រីពិការ ១នាក់ ។
- គម្រោងបានផ្តល់ធុងចម្រោះចំនួន ៩៦ឈុតដល់ ៩៦គ្រួសារ នៅ ០៥ភូមិគោលដៅ មានអ្នកទទួលផលចំនួន ៥០៨នាក់ (ប្រុស ១៤៧ ស្រី ១៤១ ក្មេងប្រុស ៩៧ ក្មេងស្រី ១១៧ បុរសពិការ ០៥ និងស្ត្រីពិការ ១នាក់)។
- គម្រោងបានជីកស្រះសហគមន៍ចំនួន ០២ នៅភូមិឬស្សីតាម៉ាន់ និងភូមិអូដែលមានអ្នកទទួលផលសរុប ២៤៧៤នាក់
- គម្រោងបានផ្តល់ឧបករណ៍លាងដៃគ្រួសារ ចំនួន ៤០ឈុតដល់សហគមន៍ចំនួន ៤០គ្រួសារ ដែមានអ្នកទទួលផល ១៩៤នាក់ (បុរស ៤១នាក់ ស្ត្រី ៦២នាក់ ក្មេងប្រុស ៣៥នាក់ ក្មេងស្រី ៥៥នាក់ បុរសពិការ២នាក់ ស្ត្រីពិការ ២នាក់

និងកុមារាពិការ ០២នាក់)។ លើសពីនេះគម្រោងបានផ្តល់ឧបករណ៍លាងដៃចំនួន ០៦ដល់សាលាបឋមសិក្សាអូ និងបត់ត្រាច ដែលនឹងផ្តលអត្ថប្រយោជន៍ដល់សិស្សចំនួន ៤៣៤នាក់ (ស្រី ២២៧នាក់)។

- គម្រោងបានសាងសង់កន្លែងលាងដៃ ១កន្លែងនៅសាលាបឋមសិក្សាសម្រោងជ័យ មានសិស្សានុសិស្សទទួលផល ១៥៩នាក់ (ស្រី ៧៥នាក់)។
- គម្រោងបានបណ្តុះបណ្តាលទឹកស្អាត និងអនាម័យសហគមន៍ដែលមានអ្នកចូលរួម ១៥២នាក់ (ប្រុស ៥៨នាក់ ស្រី ៥៤នាក់ ក្មេងប្រុស ១៧នាក់ និងក្មេងស្រី ២៣នាក់) មកពីប្រាំភូមិ។
- ប្រព័ន្ធចែកចាយទឹកមួយបានសាងសង់រួចរាល់នៅភូមិសាមគ្គី ឃុំ ស្នាមព្រះ មានលទ្ធភាពផ្គត់ផ្គង់ទឹកបាន សំរាប់ ២០ គ្រួសារមានមនុស្ស ៨១នាក់ មានបុរស ២៦នាក់ ស្ត្រី ៣១នាក់ កុម៉ារា ១៥នាក់ និងកុមារី ៩ នាក់
- គម្រោងបានផ្តលធុងចំរោះទឹករូបទន្សាយចំនួន ៥០ឈុត ដល់សហគមន៍ចំនួន ៥០គ្រួសារ សំរាប់៥ភូមិគោលដៅមានមនុស្ស ២២៧នាក់ មានបុរស ៥៣នាក់ ស្ត្រី ៨០នាក់ កុមារា ៤៤ កុមារី ៤៦ នាក់ បុរសពិការ ១នាក់ និងស្ត្រីពិការ ៣ នាក់។
- គម្រោងបានបណ្តុះបណ្តាលការគ្រប់គ្រងគ្រោះមហន្តរាយដល់គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ឃុំចំនួន ២ វគ្គមានអ្នកចូលរួម ៧៤នាក់ (ប្រុស ១១នាក់ ស្រី ៦២នាក់ និងបុរសពិការ ១នាក់)។
- គម្រោងបានសហការជាមួយគណៈកម្មការគ្រោះមហន្តរាយថ្នាក់ឃុំរៀបចំវគ្គបណ្តុះបណ្តាលគ្រប់គ្រងមហន្តរាយដល់សហគមន៍ចំនួន ០៥វគ្គ មានអ្នកចូលរួមចំនួន ១២៩នាក់ (ប្រុស ២៨នាក់, ស្រី ៨៦នាក់ ក្មេងប្រុស ៤នាក់ ក្មេងស្រី ៨ នាក់ បុរស់ពិការ១ នាក់ និងស្ត្រីពិការ ២នាក់)។
- គម្រោងបានបណ្តុះបណ្តាលគណៈកម្មគ្រោះមហន្តរា គណៈកម្មការអភិវឌ្ឍន៍ភូមិ និងអ្នកស្ម័គ្រចិត្តសុខភាពភូមិ លើការគ្រប់គ្រង់ និងកាត់បន្ថយគ្រោះមហន្តរាយ មានអ្នកចូលរួមចំនួន ២២នាក់ (ស្ត្រី ១១នាក់) មកពីប្រាំភូមិ។
- គម្រោងបានបណ្តុះបណ្តាលស្តីពីការលើកកម្ពស់សន្តិភាពមួយលើកដល់គណៈកម្មការស្ត្រី ដែលមានអ្នកចូលរួមចំនួន ២៨នាក់ (ជាស្ត្រី)។
- គម្រោងបានរៀចំទិវាសិទ្ធនារីអន្តរជាតិចំនួន ៣លើក មានអ្នកចូលរួម ១៧០នាក់ (បុរស ៣១នាក់ ស្ត្រី ១១៩នាក់ កុមារា ១១នាក់ កុមារី ៩នាក់)។
- គម្រោងបានបណ្តុះបណ្តាលស្តីពីការគ្រប់គ្រង និងភាពជាអ្នកដឹកនាំដល់គណៈកម្មការស្ត្រី មានអ្នកចូលរួម ២៤នាក់ មកពី ៥ភូមិគោលដៅ។
- គម្រោងបានបណ្តុះបណ្តាលស្តីពីការបង្កើតទំនាក់ទំនងដល់គណៈកម្មការស្ត្រី មានអ្នកចូលរួម ២៤នាក់ មកពី ៥ភូមិគោលដៅ។
- គម្រោងបានបណ្តុះបណ្តាលអំពីការព្រានប្រដៅកូនតាមបែបវិជ្ជមានចំនួន ១វគ្គដល់គណៈគម្មការស្ត្រី និងកុមារថ្នាក់ឃុំ មានអ្នកចូលរួម ២៥នាក់ ជាស្ត្រី។
- គម្រោងបានបណ្តុះបណ្តាលអំពីការព្រានប្រដៅកូនតាមបែបវិជ្ជមានចំនួន ៥វគ្គដល់សហគមន៍គោលដៅដែលមានអ្នកចូលរួម ១៤៤នាក់ (បុរស ២៧នាក់ ស្ត្រី ១១២នាក់ បុរសពិការ ៤នាក់ និងស្ត្រីពិការ ១នាក់)។
- គម្រោងបានរៀបចំប្រជុំឆ្លុះបញ្ចាំគម្រោងនៅភូមិគោលដៅដែលមានអ្នកចូលរួមចំនួន ១៥០នាក់ (បុរស ៣០នាក់ ស្ត្រី ៧២នាក់ ក្មេងប្រុស ១២នាក់ ក្មេងស្រី ២៧នាក់ បុរសពិការ ៥នាក់ និងស្ត្រីពិការ ៤នាក់)។

**គម្រោង៖** គម្រោងលើកកម្ពស់សន្តិសុខស្បៀ អាហារូបត្ថម្ភ និងជីវភាពស្ត្រី និងកុមារនៅ ៤ឃុំនៃខេត្តសៀមរាប
(Improved Food and Nutrition Security and Livelihood of women and children in four communes of Siem Reap province)

**ម្ចាស់ជំនួយ៖** Malteser International

**រយៈពេលគម្រោង៖** វិច្ឆិកា ២០១៧ ដល់ មិនា ២០២២

**តំបន់គោលដៅ៖** ស្រុកក្រឡាញ់ និងស្រុកអង្គរជុំ

**គោលបំណងគម្រោង៖** ដើម្បីលើកស្ទួយស្ថានភាពអាហារូបត្ថម្ភនិងឱកាសទទួលបាននូវរបបអាហារប្រកបដោយជីវជាតិសម្រាប់ក្រុមគ្រួសារដែលងាយរងគ្រោះ ជាពិសេសក្រុមគ្រួសារស្ត្រីឋិតក្នុងវ័យបន្តពូចនិងគ្រួសារដែលមានកុមារតូចអាយុក្រោម២ឆ្នាំ។

**សមិទ្ធផលគម្រោងអាហារូបត្ថម្ភនិងសន្តិសុខស្បៀងឆ្នាំ២០២១៖** រយៈពេលរាយការណ៍ ពីខែមករា ដល់ខែធ្នូ ២០២១ មានដូចតទៅ៖

- គម្រោងបានសហការជាមួយមណ្ឌលសុខភាពខេត្តសៀមរាប រៀបចំវគ្គបណ្តុះបណ្តាលស្រីពីការថែទាំមុន និងក្រោយសម្រាលដល់មណ្ឌលសុខភាពឃុំ និងស្រុកប្រត្តិបត្រដែលមានអ្នកចូលរួមចំនួន ១០នាក់ (ស្ត្រី ៧នាក់)
- បានផ្តល់វគ្គអប់រំអំពីអាហាររូបត្ថម្ភ និងលទ្ធភាពទទួលបានអាហារ IYCF (BFCI) និងអនាម័យខ្លួនប្រាណជារៀងរាល់ខែក្នុងភូមិគោលដៅទាំង៣០ ដោយមានអ្នកចូលរួមជាម្តាយ ជាឳពុក និងយាយតាចំនួន១២២៥នាក់ រួមមានស្រី ១១៣០នាក់ និងកុមារាចំនួន៦២៨ និងកុមារី៥៩៧ នាក់។ ក្នុងនោះ មានកុមារចំនួន១១២០នាក់ ខ្វះទម្ងន់ជាលក្ខណៈស្រាល ក្នុងនោះកុមារចំនួន១០៥នាក់។
- គម្រោងបានសហការជាមួយមណ្ឌលសុខភាពធ្វើការបណ្តុះបណ្តាលអ្នកស័គ្រចិត្តសុខភាពលើការតាមដានការលូតលាស់របស់កុមារ សម្រសម្រួល នងផ្តល់ដំបូន្មានផ្នែកសុខភាព អាហារូបត្ថម ចំនួន ១៦វគ្គ ដែលមានអ្នកចូលរួមចំនួន ២២៨ (ស្រីចំនួន ១៦០នាក់) គម្រោងបានសហការជាមួយមណ្ឌលសុខភាពធ្វើការបណ្តុះបណ្តាលលើសុខភនិងអនាម័យចំនួន ៤៦វគ្គដែលមានអ្នកចូលរួម ៩៥០នាក់ (ស្រី ៨៧៥នាក់) និងអ្នកសម្ម័ចិត្តសុខភាពភូមិចំនួន ៦០នាក់។
- គម្រោងបានផ្តល់ធុងចម្រោះចំនួន ១១៣៦ឈុត ដល់ ១១៣៦គ្រួសារនៅក្នុងភូមិគោលដៅ។
- គម្រោងបានផ្តល់កញ្ចប់អនាម័យ ៦៩០កញ្ចប់ដល់សហគន៍ចំនួន ៦៩០គ្រួសារ
- គម្រោងបានបណ្តុះបណ្តាលការដាំបន្លែជាលក្ខណៈអាជីវកម្មចំនួន ១វគ្គដែលមានអ្នកចូលរួមចំនួន ១២នាក់ (ស្រី ២នាក់)
- គម្រោងបានបណ្តុះបណ្តាលការដាំបន្លែខ្នាតតូចចំនួន ២វគ្គ ដែលមានអ្នកចូលរួមចំនួន ៥៤នាក់ (ស្រី ៤១នាក់)
- គម្រោងបានគាំទ្រសម្ភារៈកសិកម្មដល់កសិករដាំបន្លែចំនួន ៥៤គ្រួសារ
- គម្រោងបានបណ្តុះបណ្តាលការចិញ្ចឹមមាន់ខ្នាតធំដល់កសិករចំនួន ២វគ្គដែលមានអ្នកចូលរួមចំនួន ២០នាក់ (ស្រី ០៩នាក់)
- គម្រោងបានគាំទ្រសម្ភារៈ និងពូជមាន់ដល់កសិករខ្នាតធំចំនួន ២០គ្រួសារ

# ករណីសិក្សា

## មានកន្លែងលាងដៃនៅក្នុងសាលានាំមកនូវផាសុកភាព

**សាលាបឋមសិក្សាសំរោងជ័យ**មានសិស្សចំនួន១៥៩ (កុមារី៧៥ នាក់) ដែលមានទីតាំងស្ថិតនៅក្នុងភូមិសំរោង ឃុំបឹងបត់កណ្តាល ស្រុកបាកាន ខេត្តពោធិ៍សាត់។ ដោយសង្កេតឃើញថាសាលាមិនមានកន្លែងលាងដៃគ្រប់គ្រាន់សម្រាប់សិស្សប្រើប្រាស់នៅពេលដែលពួកគាត់ចេញលេងជាមួយមិត្តភក្តិ មុនពេលញ៉ាំអាហារ ក្រោយពីការសម្អាតទីធ្លាសាលារៀន បោសសម្រាម ឬក្រោយពេលដែលពួកគាត់ចេញ ពីបង្គន់អនាម័យដែលធ្វើឲ្យពួកគាត់មានអនាម័យមិនល្អ មានសុខភាពមិនប្រសើរ ស្ថានភាពសិក្សាមានភាពអាប់អួរការសិក្សារបស់ពួកគេក៏មិនបានល្អ ។ ផ្អែកលើស្ថានភាពអវិជ្ជមានទាំងអស់នេះ លោកគ្រូនាយកសាលាលោក ស៊ុន ភី បានធ្វើការស្នើសុំដល់អង្គការអភិវឌ្ឍន៍កសិករដើម្បីជួយសម្រួលដល់ អនាម័យសាលារៀន កន្លែងលាង ដៃមួយសម្រាប់សិស្សានុសិស្សអាចប្រើប្រាស់បានគ្រប់គ្រាន់ និង ធានានូវសុវត្ថិភាពកុមារ និង សុខុមាលភាពជារួម ។





ដោយឃើញនៅចំណុចគួរកែលម្អទាំងនេះ គម្រោងបានផ្តល់អោយគាត់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ។ក្នុងអំឡុងពេលសាងសង់លោកគ្រូបានមើលការខុសត្រូវរាល់សកម្មភាពរបស់ជាងសាងសង់ជៀសវាងហានិភ័យនិងគ្រោះថ្នាក់ណាមួយនៅពេលប្រើប្រាស់ ក្រោយពីបានសាងសង់កន្លែងលាងដៃរួចមកឃើញថាបរិស្ថាននៅសាលាស្អាតជាងមុនមិនមានសម្រាមដោយសាលាមានធុងសំរាម សិស្សទាំងអស់យកចិត្តទុកដាក់ក្នុងការលាងដៃជានិច្ចជាមួយសាប៊ូ ហើយតែងតែលាងដៃនៅពេលដែលពួកគាត់ចេញលេងជាមួយមិត្ត មុនពេលញ៉ាំអាហារ ឬក្រោយពេលដែលពួកគាត់ចេញពីបង្គន់អនាម័យដែលធ្វើឲ្យពួកគាត់មានអនាម័យល្អ មានសុខភាពប្រសើរ ។លោកគ្រូក៏បាននិយាយឡើងថា " ក្រោយពីបានទទួលបានកន្លែងលាងដៃនេះមកសិស្សទាំងអស់នៅសាលារបស់ខ្ញុំបានអនុវត្តន៍ការលាងដៃយ៉ាងខ្ជាប់ខ្ជួននៅពេលដែលដៃរបស់ពួកគាត់កង្វក់ និង មានភាពប្រសើរផ្នែកអនាម័យផ្សេងៗដូចជាសម្អាតបង្គន់អនាម័យ មិនចោលសំរាមក្រៅធុងសម្រាមទៀតផងចំពោះការបំពាក់បំប៉នចំនេះដឹងបន្ថែមនៃការលាងដៃ ការសម្អាតបរិស្ថាន ខ្លួនប្រាណ និងការប្រើប្រាស់បង្គន់អនាម័យពីអង្គការអភិវឌ្ឍន៍ជីវភាពកសិករ ពួកយើងនឹងព្យាយាមចែករំលែកដល់សិក្សានុសិស្សជារឿយៗ " ។ លោកគ្រូក៏បានបន្ថែមទៀត គាត់សង្ឃឹមយ៉ាងមុតមាំថា សិស្សទាំងអស់មិនអាចមានជម្ងឺរាតត្បាតផ្សេងៗដូចជា រាគរូស រមាស់ រលោកស៊ីស្បែក ឈឺពោះក្អួតចង្អោរដោយកង្វះខាតអនាម័យឡើយ ព្រោះសាលាមានគោលការណ៍ពង្រឹងសមត្ថភាពតាមពាក្យស្លោក ហូបស្អាត ផឹកស្អាត រស់នៅស្អាត ទាំងនៅសាលា និង នៅផ្ទះរបស់ពួកគាត់ ។លោកគ្រូ -អ្នកគ្រូ និងសិស្សានុសិស្សទាំងអស់ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះម្ចាស់ជំនួយ ( អង្គការ អេ.ស៊ី.អា ) តាមរយៈអង្គការអភិវឌ្ឍន៍ជីវភាពកសិករ ដែលបានឧបត្ថម្ភកន្លែងលាងដៃដល់សាលាបឋមសិក្សាបឋមសិក្សាសំរោងជ័យ ពួកគាត់ពិតជាពេញចិត្តខ្លាំងណាស់ នឹងខំថែរក្សា សម្អាត និងប្រើប្រាស់អោយកាន់តែល្អប្រសើរ។

**សាលាបឋមសិក្សាអូរ** មានសិស្សសរុបចំនួន៣០៨នាក់ (កុមារី១៥០ នាក់) និងមានគ្រូសរុបចំនួន ៦នាក់(ស្រី៣នាក់) ដែលមានទីតាំងស្ថិតនៅក្នុងភូមិអូរ ឃុំបឹងបត់កណ្ដោល ស្រុកបាកាន ខេត្តពោធិ៍សាត់។ ដោយសង្កេតឃើញថាសាលាមិនមានកន្លែងលាងដៃគ្រប់គ្រាន់សម្រាប់សិស្សប្រើប្រាស់នៅពេលដែលពួកគាត់ចេញលេងជាមួយមិត្តភក្តិ មុនពេល

ញុំាអាហារ ក្រោយពីការសម្អាតទីធ្លាសាលារៀន បោសសម្រាម ឬក្រោយពេលដែលពួកគាត់ចេញ ពីបង្គន់អនាម័យដែលធ្វើឲ្យពួកគាត់មានអនាម័យមិនល្អ មានសុខភាពមិនប្រសើរ ស្ថានភាពសិក្សាមានភាពអាប់អួរការសិក្សារបស់ពួកគេក៏មិនបានល្អ។ ផ្អែកលើស្ថានភាពអវិជ្ជមានទាំងអស់នេះ លោក **ថាន ពៅ** ជានាយកសាលា បានធ្វើការស្នើសុំដល់អង្គការអភិវឌ្ឍន៍កសិករដើម្បីជួយសម្រួលដល់អនាម័យសាលារៀន




កន្លែងលាងដៃមួយសម្រាប់សិស្សានុសិស្សអាចប្រើប្រាស់ និងធានានូវសុវត្ថិភាពកុមារ និងសុខុមាលភាពជារបស់ពួកគេ។ ដោយឃើញនៅចំណុចគួរកែលម្អទាំងនេះ គម្រោងបានផ្តល់អោយគាត់នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២១ ។ ក្នុងអំឡុងពេលសាងសង់លោកគ្រូបានមើលការខុសត្រូវរាល់សកម្មភាពរបស់ជាងសាងសង់យ៉ាងយកចិត្តទុកដាក់ជៀសវាងហានិភ័យ និងគ្រោះថ្នាក់ណាមួយនៅពេលប្រើប្រាស់។ ក្រោយពីបានសាងសង់កន្លែងលាងដៃរួចមកឃើញថាបរិស្ថាននៅសាលាស្អាតជាងមុន មិនមានសម្រាមដោយសាលាមានធុងសំរាម សិស្សទាំងអស់យកចិត្តទុកដាក់ក្នុងការលាងសំអាតដៃជានិច្ចជាមួយសាប៊ូហើយតែងតែលាងដៃនៅពេលដែលពួកគាត់ចេញលេងជាមួយមិត្ត មុនពេលញុំាអាហារ ឬក្រោយពេលដែលពួកគាត់ចេញពីបង្គន់អនាម័យដែលធ្វើឲ្យពួកគាត់មានអនាម័យល្អ។ លោកគ្រូក៏បាននិយាយឡើងថា " ក្រោយពីបានទទួលបានកន្លែងលាងដៃនេះមក និងការផ្សព្វផ្សាយចំនេះដឹងផ្នែកអនាម័យផ្សេងៗ សិស្សទាំងអស់នៅសាលារបស់ខ្ញុំបានអនុវត្តន៍ ការលាងដៃយ៉ាងខ្ជាប់ខ្ជួននៅពេលដែល ដៃរបស់ពួកគាត់មិនស្អាត និងមានភាពប្រសើរផ្នែកអនាម័យផ្សេងៗ ដូចជាសម្អាតបង្គន់អនាម័យ ចោលសំរាមក្នុងធុងសម្រាម ចំពោះការផ្តល់ចំនេះដឹងបន្ថែមនៃការលាងដៃ ការសម្អាតបរិស្ថាន ខ្លួនប្រាណ និងការប្រើប្រាស់បង្គន់អនាម័យពីអង្គការអភិវឌ្ឍន៍ជីវភាពកសិករ ខ្ញុំ និងលោកគ្រូ អ្នកគ្រូផ្សេងទៀត បានព្យាយាមបន្តការចែករំលែកចំនេះដឹងផ្នែកអនាម័យដល់សិក្សានុសិស្សជាប្រចាំ សាលាក៏មានពាក្យស្លោក ហូបស្អាត ផឹកស្អាត រស់នៅស្អាត " ។ លោកគ្រូក៏បានបន្ថែមទៀត គាត់សង្ឃឹមយ៉ាងមុតមាំថា សិស្សទាំងអស់នឹងមានសុខភាពល្អ មិនមានជម្ងឺរាគត្បាតផ្សេងៗដូចជា រាគរូស រមាស់ ឈឺពោះក្អួតចង្អោរដោយកង្វះខាតអនាម័យទៀតទេ។ តាមរយៈសកម្មភាពអនាម័យទាំងនេះ បានធ្វើអោយសិស្សរបស់ខ្ញុំមានទំលាប់ល្អ ក្នុងការរស់នៅ ក៏បានផ្លាស់ប្តូរឥរិយាបថរស់នៅ ដែលនាំអោយពួកគេ មានសុខភាពល្អ ទទួលបានភាពវៃឆ្លាត និងលទ្ធផលនៃការសិក្សាប្រសើរជាងមុន ។ លោកគ្រូ -អ្នកគ្រូ និងសិស្សានុសិស្សទាំងអស់ សូមថ្លែងអំណគុណយ៉ាងជ្រាលជ្រៅចំពោះម្ចាស់ជំនួយ (អង្គការ អេ.ស៊ី.អា អូស្ត្រាលី) តាមរយៈអង្គការអភិវឌ្ឍន៍ជីវភាពកសិករ ដែលបានឧបត្ថម្ភកន្លែងលាងដៃ លើកកម្ពស់ចំណេះដឹងផ្នែកអនាម័យ ដល់សាលាបឋមសិក្សាអូរ ពួកយើងពិតជាពេញចិត្តខ្លាំងណាស់ នឹងខំថែរក្សា សម្អាត និងប្រើប្រាស់អោយកាន់តែល្អប្រសើរ។

## សុខភាពប្រសើដោយសាធុងចម្រោះ



លោកស្រី ស៊ុម រឿនមានអាយុ៦៩ឆ្នាំ ជាប្រជនរស់នៅក្នុងភូមិអូរ ឃុំបឹងបត់កណ្តោល ស្រុកបាកាន ខេត្តពោធិ៍សាត់។ គ្រួសាររបស់គាត់មានសមាជិកចំនួន០៦នាក់ ស្រ្តី ០៣នាក់ បុរស០២នាក់ និងកុមារី០១នាក់។ គាត់ជាស្រ្តីមេម៉ាយដែលរស់នៅជាមួយកូនស្រីរបស់គាត់។ គាត់ក៏ជាស្រ្តីមេផ្ទះដែលនៅថែទាំចៅស្រីរបស់គាត់។ កូនស្រ្តីរបស់បានធ្វើចំណាក់ស្រុកទៅប្រទេសថៃដើម្បីរកចំណូលមកផ្គត់ផ្គង់គ្រួសារទាំងមូល រួមមាន ការហូបចុច ការផឹក ការបង់សេវាថ្លៃព្យាបាល និងសម្ភារៈសិក្សា។ កុឡុងពេលរាតត្បាតនៃជម្ងឺកូវីដ១៩ កូនគាត់រកចំណូលមិនបានទេ។

អង្គការអភិវឌ្ឍន៍ជីវភាពកសិករ ជាអង្គការដែលមិនស្វែងរកប្រាក់ចំណូល ដែលមានទីតាំងនៅក្នុងខេត្តពោធិ៍សាត់ និងអនុវត្តន៍គម្រោងទៅជីវភាព និងផ្នែកអនាម័យ។ FLD តែងតែយកចិត្តទុកដាក់ទៅលើក្រុមគ្រួសារក្រីក្រ និងអង្កេតមើលពីកង្វះខាត់របស់ពួកគេ។ ជាពិសេស FLD បានសង្កេតមើលពីរបបអាហារ និងការប្រើប្រាស់ទឹកមិនបានសមរម្យ។ ពីមុនក្រុមគ្រួសាររបស់គាត់ប្រើប្រាស់ទឹកភ្លៀងសម្រាប់បរិភោគ និងទឹកដាំពុះជាញឹកញាប់ ហើយពេលខ្លះពួកគាត់ទិញទឹកពីអ្នកលក់ក្នុងតម្លៃ១៥ថ្ងៃ បានប្រើប្រាស់បាន។ វាជាហេតុ៥រៀល ក្នុងមួយធុង ក្រោយមកគាត់ទុកទឹកនោះក្នុងពាងបិតគ្របរយៈពេល០០០, ផលមួយដែលនាំអោយពួកគាត់មានបញ្ហា ឈឺក្រពះ រាករូស ឈឺក្បាល និងមេរោគក្រពះ។ នេះជាមូលហេតុចម្បងដែលនាំអោយគាត់ខាតពេលវេលា លុយកាក និងក្មេងៗរៀនមិនសូវចេះ។ម្យ៉ាងវិញទៀតគ្រួសាររបស់គាត់ខ្វះខាតលុយដើម្បីទិញធុងចម្រោះទឹកស្អាត។ ក្រោយពីគាត់បានចូលរួមយ៉ាងសកម្មហើយ គាត់ក៏បានយល់កាន់តែច្បាស់ពីសសារសំខាន់នៃការបរិភោគទឹកស្អាត។ ដូចនេះគាត់មានបដិភាគដើម្បីចូលរួមគម្រោង គាត់ក៏សម្រេចចិត្តស្នើសុំធុងចម្រោះទឹកស្អាតពីគម្រោង។

FLD បានអនុវត្តន៍គម្រោងលើ ប្រព័ន្ធចែកចាយទឹកស្អាត បង្គន់អនាម័យ ធុងស្តុបទឹក ធុងចម្រោះ និងអនាម័យ ហើយបុគ្គលិកFLDបានធ្វើការប្រជុំផ្សព្វផ្សាយពីគម្រោងទៅដល់ពួកគាត់។ ហើយម្យ៉ាងវិញទៀត គាត់ក៏បានចូលរួមវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ដែលរៀបចំឡើងដោយ FLDប្រចាំខេត្តពោធិ៍សាត់។

ភូមិសាមគ្គី គឺជាភូមិមួយ ក្នុងចំណោមភូមិគោលដៅចំនួនប្រាំ ដែលអង្គការអភិវឌ្ឍន៍ជីវភាពកសិករ កំពុងធ្វើការគាំទ្រ និងអនុវត្តន៍ ហើយភូមិនេះមានចម្ងាយប្រមាណ ១៤គីឡូម៉ែត្រ ពីទីរួមខេត្តពោធិ៍សាត់។ នៅក្នុងភូមិសាមគ្គី មាន២០៦ខ្នងផ្ទះ ស្មើនឹង២០៩គ្រួសារ ប្រជាជនសរុបចំនួន៩៣៥នាក់ ស្រ្តីចំនួន៤៩១នាក់ ដែលក្នុងនោះប្រជាជនមានប័ណក្រីក្រ ក្រ១ចំនួន១២គ្រួសារ និងក្រ២ ចំនួន៣០គ្រួសារ។ ប្រជាជននៅទីនោះប្រកបរបរចិញ្ចឹមជីវិតដោយផ្អែកលើការដាំដំណាំស្រូវ

ចិញ្ចឹមសត្វ លក់ដូរ ស៊ីឈ្នួលគេ និងចំណាក់ស្រុកទៅធ្វើការនៅប្រទេសថៃ ។ FLD បាននឹងកំពុងអនុវត្តន៍គម្រោងលើប្រព័ន្ធចែកចាយទឹកស្អាត បង្គន់អនាម័យ ធុងស្តុបទឹក ធុងចម្រោះ និងអនាម័យ ហើយបុគ្គលិកFLDបានធ្វើការប្រជុំផ្សព្វផ្សាយពីគម្រោងទៅដល់ប្រជាជនក្នុងភូមិ។ ហើយពួកគេទាំងអស់ត្រូវបានធ្វើការពង្រឹងផ្នែក ចំណេះដឹងទូទៅតាមរយៈគម្រោងដូចជា យុទ្ធនាការផ្សព្វផ្សាយ រៀនសូត្រ និងសហគមន៍អនុវត្តន៍អនាម័យ យុទ្ធនាការអនាម័យបរិស្ថានភូមិ ការលើកកម្ពស់ចំណេះដឹងស្តីពីសិទ្ធិស្រ្តី និងបញ្ហាស្រ្តី ស្រ្តីក្នុងភាពជាអ្នកដឹកនាំ ការលើកកម្ពស់ចំណេះដឹងស្តីពីការទប់ស្កាត់ការឆ្លងរាតត្បាតជម្ងឺកូវីដ-១៩ផងដែរ។




លោកស្រី ឡុង បូរី មានអាយុ ៣៩ឆ្នាំ រស់នៅជាមួយប្តីរបស់គាត់ឈ្មោះ ឡុង ថន អាយុ៤០ឆ្នាំ នៅក្នុងភូមិសាមគ្គី ឃុំស្នាមព្រះ ស្រុកបាកាន ខេត្តពោធិ៍សាត់ ប្រទេសកម្ពុជា។ ពួកគាត់រៀបការកាលពីឆ្នាំ២០០៤ ហើយមានកូនស្រីពីរនាក់ និងកំពុងទំងន់៥ខែ និងមានក្មួយស្រីម្នាក់នៅក្នុងបន្ទុកគ្រួសារ ដែលកូនស្រីទី១ ឈ្មោះ ឡូញ ស៊ីអ៊ី អាយុ១៥ឆ្នាំ រៀនថ្នាក់ទី៧(ឈប់រៀន១ឆ្នាំ) កូនស្រីទី២ ឈ្មោះ ឡូញ ជីអ៊ុន អាយុ១២ឆ្នាំ កំពុងរៀនថ្នាក់ទី៥ នៅសាលាបឋមសិក្សាខ្នារ និងក្មួយស្រីឈ្មោះ រី ម៉េងជូ អាយុ ០៥ ឆ្នាំ។ បន្ទាប់ពីរៀបការមក គាត់បានចំណាក់ស្រុកទៅធ្វើការនៅប្រទេសថៃជារៀងរាល់ឆ្នាំ និងប្រកបមុខរបរធ្វើសំណង់ ស៊ីឈ្នួលគេ និងចិញ្ចឹមមាន់(២០ក្បាល) ដើម្បីរកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារ។ សព្វថ្ងៃគាត់ជាគ្រួសារក្រីក្រដែលមានប័ណ្ណក្រីក្រ ក្រ១ ចេញឆ្នាំ២០២០ រស់នៅក្នុងផ្ទះដែលមានទំហំ (៤មx ៥ម) សង់ពីឈើ ដំបូលប្រក់សង្កសី និងជញ្ជាំងធ្វើពីសង្កសី។នៅមុនពេលចូលគម្រោងស្ថានភាពនៃការប្រើប្រាស់ទឹកស្អាតក្នុងគ្រួសារលោកស្រី មិនសូវល្អនោះទេ ដោយសារមិនមានលទ្ធភាពទិញធុងចម្រោះទឹកស្អាតប្រើប្រាស់។ រាល់ថ្ងៃក្នុងគ្រួសាររបស់គាត់ត្រូវចំណាយពេល២ម៉ោងទៅ៣ម៉ោងដើម្បីដាំទឹកហូបចំនួន៥កំសៀវ ដោយប្រើចង្រ្កានដុតអុស និងត្រូវទៅរកអុសយកមកប្រើប្រាស់ដែរមានចំងាយប្រហែល២គីឡូម៉ែត្រដោយជិះកង់។ ពេលខ្លះក៏ត្រូវសុំទឹកចម្រោះអ្នកជិតខាងចំងាយ១០០ម៉ែត្រ ចំនួន៥លីត្រក្នុងមួយថ្ងៃ ដើម្បីហូប ដោយសារមេឃភ្លៀងពិបាកទៅរកអុសមកប្រើប្រាស់។ ជួនកាលគ្រួសាររបស់គាត់ត្រូវហូបទឹកឆៅ ដោយមិនបានដាំពុះ ព្រោះមិនហានសុំទឹកចំរោះ និងយល់ថាទំលាប់ហូបទឹកឆៅពីមុនមកមិនប៉ះពាល់សុខភាពទេ។ កាលពីឆ្នាំ២០១៨ ប្តីរបស់គាត់ បានកើតជំងឺគ្រុនពោះវៀន ដែលត្រូវចំណាយលើការព្យាបាលអស់១លានរៀល ហើយកូនៗក៏មានជំងឺឈឺក្រពះ រាករូស ឈឺក្បាល និងមេរោគក្រពះ។ នេះជាមូលហេតុចម្បងដែលនាំអោយគាត់ខាតពេលវេលា លុយកាក់ និងក្មេងៗរៀនមិនសូវចេះ។ បើគិតទៅលើការចំណាយទៅលើការព្យាបាលជំងឺ ជារៀងរាល់ឆ្នាំ គាត់ត្រូវបានចំណាយប្រហែលពី១លានរៀល ទៅ២លានរៀលក្នុងមួយឆ្នាំ។ ដោយសារតែការចំណាយខ្ពស់

ទៅលើការព្យាបាលជំងឺនេះហើយ ទើបធ្វើអោយពួកគាត់មានជីវភាពខ្សត់ខ្សោយ ពេលខ្លះនៅពេលដែលមានជំងឺកើតឡើង ហើយ មិនមានលុយ គាត់ត្រូវទៅខ្ចីលុយគេសិន លុះដល់ទៅធ្វើការនៅប្រទេសថៃទើបបានមានលុយសល់គេ។

លោកស្រី ឡុង បូរី បានចូលរួមក្នុងគម្រោងនៅក្នុងឆ្នាំ២០២០ ជាអ្នកទទួលផលពីគម្រោងនៅក្នុងក្រុមកសិករក្រីក្រ ទទួលសម្ភារៈអាងស្តុកទឹក ទទួលធុងចម្រោះ ទទួលធុងទឹកលាងដៃ និងទទួលបានស្បៀងបន្ទាន់។ នៅពេលគាត់ចូលរួមជាមួយគម្រោង គាត់បានចូលរួមនៅក្នុងយុទ្ធនាការលាងសម្អាតដៃ យុទ្ធនាការអនាម័យសហគមន៍ដែលសម្របសម្រួលដោយបុគ្គលិកសម្របសម្រួលអភិវឌ្ឍន៍សហគមន៍។ នៅក្នុងកម្មវិធីទាំងនេះគាត់បានរៀនសូត្រយ៉ាងយកចិត្តទុកដាក់ ចូលរួមយ៉ាងសកម្ម ហើយក៏បានយកទៅអនុវត្តន៍ជាប្រចាំថ្ងៃ។ ហើយលោកស្រីក៏បានចូលរួម យុទ្ធនាការអនាម័យផ្សេងៗដូចជា យុទ្ធនាការអនាម័យខ្លួនប្រាណ ដែលធ្វើអោយគាត់ចេះពីរបៀបលាងដៃបានត្រឹមត្រូវ ការសម្អាតផ្ទះសម្បែង ការជំរុញការប្រើប្រាស់បង្គន់អនាម័យ។ ចូលរួមយុទ្ធនារការអនាម័យ បរិស្ថាន ដែលធ្វើអោយគាត់ចេះរៀបចំ ធ្វើអនាម័យជុំវិញផ្ទះ និងកាបស្ការព្រៃជុំវិញផ្ទះអោយស្រលះ។ ក្រោយពីគាត់បានចូលរួមយ៉ាងសកម្មហើយ គាត់ក៏បានយល់កាន់តែច្បាស់ពីសារសំខាន់នៃការបរិភោគទឹកស្អាត។ ដូចនេះគាត់មានបដិភាគដើម្បីចូលរួមគម្រោង គាត់ក៏សម្រេចចិត្តស្នើសុំធុងចម្រោះទឹកស្អាតពីគម្រោង។



លោកស្រី ឡុង បូរី បានលើកឡើងថា "ការដែលមិនមានធុងចម្រោះប្រើប្រាស់ វាមិនងាយស្រួលលទេដែលត្រូវសុំទឹកចម្រោះពីអ្នកជិតខាងជារៀងរាល់ថ្ងៃនោះទេ ជាពិសេសសំរាប់ស្ត្រីដែលមានផ្ទៃពោះត្រូវចូលព្រៃរងអុសដើម្បីដាំទឹក។ ការដែលហូបទឹកឆៅ ធ្វើអោយសមាជិកនៅក្នុងគ្រួសារឧស្សាហ៍កើតមានជំងឺចំណូលដែលរកបានត្រូវចំណាយតែលើថ្នាំពេទ្យ ។ ប៉ុន្តែតាមរយៈការផ្តល់ចំណេះដឹងពីគម្រោង គ្រួសារខ្ញុំអាចធ្វើការផ្លាស់ប្តូរទំលាប់ នៃការហូបទឹកមិនស្អាត មកហូបទឹកដែលមានសុវត្ថិភាពវិញ។ ក្រោយពេលប្តូរមកប្រើប្រាស់ធុងចម្រោះដោយខ្លួនឯងវិញ ធ្វើអោយគ្រួសារនាងខ្ញុំ មានទឹកស្អាតហូបជាទៀងទាត់ និងមិនសូវកើតនូវជំងឺធំ ដូចជាគ្រុនពោះវៀន ឬឈឺក្រពះ រាគរូសទៀតឡើយ។ ហើយជីវភាព ខ្ញុំក៏បានប្រសើរឡើង ដោយមិនត្រូវបានចំណាយខ្ពស់ក្នុងការព្យាបាលជំងឺច្រើន។ នាងខ្ញុំអាចមានលទ្ធភាព ក្នុងការចំណាយលើការបរិភោគអាហារបានល្អប្រសើរជាងមុន មិនត្រឹមតែប៉ុណ្ណោះខ្ញុំក៏បានផ្គត់ផ្គង់ដល់កូនស្រីច្បងរបស់ខ្ញុំអោយចូលរៀនវិញ នៅថ្នាក់ទី៧ នៅសាលាអនុវិទ្យាល័យខ្នារឡើងវិញបន្ទាប់ពីបានឈប់រៀននៅថ្នាក់ទី៦កាលពីឆ្នាំ២០២០។ លើសពីនេះទៅទៀតខ្ញុំពិតជាសប្បាយរីករាយខ្លាំងណាស់ ជាមួយ អង្គការ FLD ដែលបានធ្វើការគាំទ្រខ្ញុំ នៅក្នុងសកម្មភាពជាច្រើន ជាពិសេសការផ្តល់ធុងចម្រោះនេះឡើង ហើយជាផ្នែកមួយសំខាន់ក្នុងការធ្វើអោយប្រសើរឡើងក្នុងការផ្លាស់ប្តូរទំលាប់មិនល្អ ដែលជួយអោយការធ្វើអនាម័យបានល្អប្រសើរ និងការកាត់បន្ថយភាពក្រីក្រ ទូទាំងភូ

មិ។ នៅថ្ងៃខាងមុខ ខ្ញុំនឹងធ្វើការចែករំលែកនូវចំនេះដឹង និងបទពិសោធន៍ ក្នុងការធ្វើអនាម័យនៅក្នុងគ្រួសារ និងចែករំលែកអំពីការសារប្រយោជនៃការប្រើប្រាស់ហូបទឹកស្អាត និងការអនុវត្តន៍អនាម័យអោយបានទូលំទូលាយ។ លោកស្រី ឡុង បូរី បាននិយាយថា "ខ្ញុំរីករាយខ្លាំងណាស់ ដែលអង្គការ FLD ក្រោមជំនួយពី ACR អូស្ត្រាលី ដែលបានគាំទ្រខ្ញុំ អោយទទួលបានធុងចម្រោះប្រើប្រាស់ និងលើកទឹកចិត្តដល់រូបខ្ញុំគ្រប់ពេល ក្នុងការគាំទ្រនូវ ចំណេះដឹងនានា វាពិតជាធ្វើឲ្យគ្រួសាររបស់ខ្ញុំមានកំរិតជីវភាពប្រសើរឡើង តាមរយៈការអនុវត្តអនាម័យបានល្អ កាត់បន្ថយជំងឺ និងកាត់បន្ថយការចំណាយ។ វាមិនត្រឹមតែរូបខ្ញុំម្នាក់នោះទេ ថែមទាំងប្រជាជននៅក្នុងសហគមន៍ទាំងមូលផងដែរ ដែលធ្វើឲ្យមានការកាត់បន្ថយភាពក្រីក្រតាមរយៈការរស់នៅស្អាតមានអនាម័យ និងការលើកកម្ពស់ចំណេះដឹងសង្គម"។

## អាងត្រងទឹកភ្លៀងជួយអោយអនាម័យគ្រួសារប្រសើ

លោកស្រី ម៉ម ម៉ាក់ ភេទស្រី មានអាយុ៦៨ឆ្នាំ ជាប្រជាជនរស់នៅក្នុងភូមិអូរ ឃុំបឹងបត់កណ្ដាល ស្រុកបាកាន ខេត្តពោធិ៍សាត់ គ្រួសារលោកស្រីសរុបមានសមាជិក០៦នាក់ បុរស០១ ស្ត្រី០២នាក់ កុមារី០២នាក់ និងកុមារ៉ា០១នាក់។ លោកស្រីរស់នៅជុំក្រុមគ្រួសារជាមួយកូន និងជួយមើលថែរក្សាចៅៗរបស់គាត់ រួមទាំងជួយការងារនៅក្នុងផ្ទះដូចជា៖ ដាំបាយ ធ្វើម្ហូប លាងចាន ដាំដំណាំក្បែរផ្ទះ។ ចំណែកឯកូនៗដែលនៅវ័យក្មេងមានកម្លាំង ពួកគេចេញទៅរកស៊ីឈ្នួល តាមតំបន់ឆ្ងាយៗ។ នៅក្នុងភូមិអូរជាតំបន់មួយមិនសូវមានទឹកប្រើប្រាស់គ្រប់គ្រាន់ឡើយ ដូចនេះថវិការដែលរកបានមកត្រូវចំណាយលើ




ការទិញទឹកស្តុបទុកប្រើប្រាស់ ឬក៏ត្រូវទិញពាងទឹកជាច្រើនដើម្បីដាក់ទឹក។ ភូមិអូរ ជាភូមិគោលដៅមួយក្នុងចំណោមភូមិគោលដៅទាំង០៥ របស់អង្គការអភិវឌ្ឍន៍ជីវភាពកសិករ។ រាល់ការខ្វះខាត របស់សហគមន៍ បុគ្គលិក ព្រមទាំងថ្នាក់ដឹកនាំតែងតែយកចិត្តទុកដាក់ និងរៀបចំផែនការសម្រាប់អភិវឌ្ឍន៍នៅក្នុងតំបន់គោលដៅ។ តួយ៉ាងដូចនៅភូមិអូរតែងតែមានបញ្ហាខ្វះខាតទឹកស្អាតប្រើប្រាស់ FLD បានអនុវត្តន៍គម្រោងសហគមន៍កាន់តែប្រសើរ រួមមានសកម្មភាព គាំទ្រជីកស្រះសហគមន៍រៀបចំវគ្គបណ្តុះបណ្តាលពីការរៀបចំផែនការគ្រប់គ្រងគោះមហន្តរាយ និងវគ្គបណ្តុះ ,គាំទ្រសម្ភារៈអាងស្តុបទឹក , បណ្តាលទាក់ទងនឹងផ្នែកអនាម័យ ទឹកស្អាតជាដើម។ ក្រោយពីមានការផ្សព្វផ្សាយយ៉ាងទូលំទូលាយនៅក្នុងសហគមន៍មក លោកស្រីក៏បានសម្រេចចិត្តស្នើសុំសម្ភារៈអាងស្តុកទឹកតាមរយៈមេភូមិ ហើយម្យ៉ាងវិញទៀតលោកស្រីមានជីវភាពក្រីក្រ ដូចនេះគាត់សន្សំខ្លះ ហើយសុំពីកូនៗខ្លះ បានគ្រប់ចូលបដិភាគ ៨០រៀល។ ក្រោយពីទទួលបានសម្ភារៈទាំង០០០,

អស់មក លោកបានអោយកូនៗគាត់រៀបចំតំឡើងយ៉ាងរហ័យ ដើម្បីឆាប់បានប្រើប្រាស់ និងត្រងទឹកភ្លៀង។ លោកស្រីមានប្រសាសន៍ថា "ពេលមានអាងស្តុកទឹក បានជួយសម្រួលបានច្រើន ងាយស្រួលប្រើប្រាស់ អាចដាក់ទឹកបានច្រើន ចំណេញថវិការ សុវត្ថិភាព ហើយថៅៗងាយស្រួលក្នុងការយកទឹកប្រើប្រាស់"។ ដោយមានគាំទ្រកញ្ចប់ថវិការពីអង្គការ ACR បានផ្តល់ជំនួយតាមរយៈ FLD ដើម្បីអនុវត្តន៍គម្រោងសហគមន៍កាន់តែប្រសើរ ហើយថវិការទាំងអស់បានជួយដល់សហគមន៍ទាំងអស់។ លោកស្រីតំណាងអោយប្រជាជនទាំងអស់ សូមថ្លែងអំណរគុណដល់ម្ចាស់ជំនួយ ដែលបានគាំទ្រ និងការជួយបណ្តុះបណ្តាល ផ្សាព្វផ្សាយចំណេះដឹង ផ្នែកទឹកស្អាត និងអនាម័យនៅក្នុងភូមិ ហើយសូមជូនពរអោយមានអាយុវែង និងសុខភាពល្អទាំងអស់គ្នា។

## សុខភាពល្អ ក្រោយពេលទទួលបានបង្គន់អនាម័យ

បងស្រី ឡាយ ផា អាយុ ៤៩ឆ្នាំ ជាកសិករមួយរូបដែលរស់នៅភូមិអូរ ឃុំបឹងបត់កណ្តោល ស្រុកបាកាន ខេត្តពោធិសាត់ ។ បងស្រី ជាកសិករម្នាក់ក្នុងចំណោមគ្រួសារក្រីក្រ ( ក្រ១) គាត់មានសមាជិករស់នៅបច្ចុប្បន្ន០៤នាក់ ( ស្រីទាំង០៤នាក់ ) ដោយសារជីវភាពខ្វះខាត គាត់មិនបានសាងសង់បង្គន់អនាម័យសម្រាប់ប្រើប្រាស់ទេ ។




គាត់បាននិយាយថា " គាត់ពិតជាលំបាក ដោយសារគ្រួសារខ្ញុំពិតជាទីទល់ក្រ ហើយប្រាក់ដែលរកបានគឺ សម្រាប់ផ្គត់ផ្គង់ជីវភាព ហើយទទឹមនឹងនោះគាត់ត្រូវគ្រប់គ្រងកូនៗតូច០២នាក់ទៀតដោយកនស្រីច្បងរបស់គាត់មានស្មារតីមិនប្រក្រតី ហើយម្តាយរបស់គាត់ក៏ធ្ងន់ត្រចៀកខ្លាំង ប្រាក់ដែលរកបានបន្តិចបន្តួចបងស្រី ត្រូវផ្គត់ផ្គង់លើម្ហូបអាហារ ការរៀនសូត្រ ទិញថ្នាំសង្កូវនៅពេលមានជម្ងឺ និង ទិញសំលៀកបំពាក់របស់ពួកគាត់ ហើយអ្វីដែលគាត់ព្រួយបារម្ភអំពីអនាម័យ នៅក្នុងគ្រួសាររបស់បងស្រី ។ គាត់បានចូលរួមប្រជុំជាមួយគម្រោងជាច្រើនលើកគាត់បានយល់កាន់តែច្បាស់អំពីអនាម័យសុខភាពប៉ុន្តែគាត់នៅតែគ្មានលទ្ធភាពក្នុងការចូលរួមបដិភាគ ។ គាត់បានចូលរួមបដិភាគម្ភៃប្រាំម៉ឺនរៀលក្នុងការសាងសង់ និងទទួលការគាំទ្របង្គន់អនាម័យពីអង្គការអភិវឌ្ឍន៍ជីវភាពកសិករនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១។ ក្រោយពីទទួលបានបង្គន់អនាម័យ គាត់សប្បាយចិត្តណាស់ ថែមទាំងបាននិយាយថា " ខ្ញុំពិតជាត្រេកអរណាស់ ដែលអង្គការអភិវឌ្ឍន៍កសិករ បានជួយឧបត្ថម្ភបង្គន់អនាម័យ ខ្ញុំលែងបារម្ភពីការប្រឈរមុខនឹងគ្រោះថ្នាក់ផ្សេងៗដោយយថាហេតុ ហើយកូនៗរបស់ខ្ញុំទទួលបានសុខភាពល្អ " ។ ហើយគាត់ក៏បានថែម

ទៀតថា គាត់បានសមបំណងកូនៗរបស់គាត់ហើយ ព្រោះពួកគាត់ បានស្នើសុំអោយមានបង្គន់អនាម័យនៅក្នុងផ្ទះ ។ ក្រោយពីគាត់សាងសង់រួចរាល់ឃើញថា គាត់មានភាពពេញចិត្តក្នុងការប្រើប្រាស់ មានការថែរទាំដិតដល់ សម្អាតបរិស្ថានជុំវិញ បានត្រឹមត្រូវ ព្រមទាំងព្រមទាំងប្រើប្រាស់ ប្រកបដោយគុណភាពផងដែរ ហើយគ្រួសារគាត់អស់កង្វល់ពីជម្ងឺដែលបង្កដោយសារគ្មានបង្គន់ទៀតហើយ កូនគាត់ពិតជាស្រឡាញ់បង្គន់អនាម័យខ្លាំងណាស់ ហើយបានដាំផ្កាលំអរទៀតផង។ ក្នុងបង្គន់នេះមានអាងទឹកតូចល្មមដែលមានទំហំ០,៣២៤ម៣ ស្មើនឹងបរិមាណទឹក៣២៤លីត្រ គ្រួសារគាត់ងាយស្រួលងូតទឹក និងប្រើប្រាស់ សម្អាត គាត់តែងតែសម្អាតនៅរាល់ពេលដែលមានភាពកខ្វក់ និងបង្រៀនកូនៗអោយចូលរួមក្នុងការសម្អាត ហើយមានការចូលរួមសម្អាតបរិស្ថានជុំវិញផ្ទះបានស្អាតទៀតផង ។ បងស្រី បានថ្លែងអំណគុណយ៉ាងខ្លាំងចំពោះម្ចាស់ជំនួយ ( អង្គការ អេ.ស៊ី.អា ) តាមរយៈ អង្គការអភិវឌ្ឍន៍ជីវភាពកសិករ ដែលបានឧបត្ថម្ភបង្គន់អនាម័យឲ្យបានកើតចេញជារូបរាងឡើង ហើយបងស្រីនឹងខំថែរក្សា សម្អាត និងប្រើប្រាស់អោយកាន់តែល្អប្រសើរ។

# ករណីសិក្សា/ការអនុវត្តន៍ ដែលមានភាពជោគជ័យ

## ភាពជោគជ័យនៃការអនុវត្តន៍បច្ចេកទេសដំណាំស្រូវ ដោយប្រើប្រាស់ឧបករណ៍ពង្រូសជាជួរ (ត្រាំស៊ីតឌ័រ) និង ការស្ទូង

បច្ចេកទេសដំណាំស្រូវ





ការអនុវត្តន៍បច្ចេទសដំណាំស្រូវ របស់កសិករនៅភូមិចន្លាសដៃ ឃុំចន្លាសដៃ ស្រុកក្រឡាញ់ ខេត្តសៀមរាប។

អង្គការអភិវឌ្ឍន៍ជីវភាពកសិករ(Farmer Livelihood Development)គឺជា អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកធ្វើការគាំទ្រសហគមន៍នៅតាមជនបទ និង គ្រួសារក្រីក្រទាំងឡាយអោយមានមុខរបរចិញ្ចឹមជីវិតកាន់តែប្រសើរឡើង។

ដោយមានការជួយឧបត្ថម្ភថវិកាពីមូលនិធិរបស់ក្រសួង សហប្រតិបត្តិការអភិវឌ្ឍន៍ សេដ្ឋកិច្ចនៃប្រទេសអាល្លឺម៉ង់តាមរយៈអង្គការម៉ាល់តេសឺអន្តរជាតិ អង្គការអភិវឌ្ឍន៍ជីវភាពកសិករបានអនុវត្តន៍គម្រោងមួយមានឈ្មោះថាៈ គម្រោងអាហារូបត្ថម្ភ និង គម្រោងសន្តិសុខស្បៀង បានប្រតិបត្តិការនៅក្នុង៣០ភូមិ ០៤ឃុំ ០២ស្រុក នៃខេត្តសៀមរាប បានជ្រើសរើសលោកពូ ឆាយ ស៊ិន គឺជា កសិកររស់នៅភូមិចន្លាសដៃ ឃុំចន្លាសដៃ ស្រុកក្រឡាញ់ ខេត្តសៀមរាប ដើម្បីចូលរួមអនុវត្តន៍បច្ចេកទេសដំណាំស្រូវ ដោយប្រើប្រាស់ ឧករណ៍ពង្រូសជាជួរ (ត្រាំស៊ីតឌ័រ និង ការស្ទូង)ជាមួយគម្រោង តាំងពីថ្ងៃទី២១ ខែ មិនា ឆ្នាំ២០១៩ រហូតមកទល់នឹងបច្ចុប្បន្ននេះ។

តាមរយៈនៃការអនុវត្តន៍គម្រោង លោកពូ ឆាយ ស៊ិន ទទួលបាននូវវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសដំណាំស្រូវ, ឧបករណ៍ត្រាំស៊ីតឌ័រចំនួន០១ គ្រឿង និងពូជស្រូវផ្ការំដួលចំនួន៤០គីឡូក្រាមដើម្បី យកទៅអនុវត្តន៍នៅក្នុងផលិតកម្មដំណាំស្រូវតាមបច្ចេកទេសរបស់គាត់។

ក្រោយពីទទួលបានវគ្គបណ្តុះបណ្តាលរួចមក លោកពូ ឆាយ ស៊ិន បានប្រើប្រាស់នូវចំណេះដឹងលើបច្ចេកទេសផលិតកម្មដំណាំស្រូវ ដោយអនុវត្តន៍តាមបច្ចេកទេសដូចជាៈភ្ជួររាស់ដីហ្មត់ល្អ និងប្រើជីកំប៉ុស្តទ្រាប់បាត, ប្រើពូជផ្ការំដួលពង្រូសតាមឧបករណ៍ត្រាំស៊ីតឌ័រ, បោចស្មៅដាក់ជីបំប៉ន និងបាញ់ថ្នាំសំលាប់សត្វល្អិតចង្រៃ និងប្រមូលផល។ ចំពោះការអនុវត្តន៍ផលិតកម្មដំណាំស្រូវរបស់គាត់ បាននូវជួបបញ្ហាគ្រោះធម្មជាតិរាំងស្ងួតនៅចន្លោះខែសីហាដល់ ខែកញ្ញា ឆ្នាំ២០១៩ និងនៅខែកញ្ញា ឆ្នាំ២០២០ ដែលធ្វើអោយស្រូវរបស់គាត់រងផលប៉ះពាល់នៅក្នុងដំណាក់កាលស្រូវកំពុងមូរដើម និងចេញកគួរ។

នៅឆ្នាំ២០១៩ គាត់ធ្វើលើផ្ទៃដីចំនួន០.៣ហ.ក ប្រើពូជចំនួន ៣០គីឡូក្រាម ហើយឆ្នាំ២០២០ គាត់ធ្វើលើផ្ទៃដីចំនួន០.៣ហ.ក ប្រើពូជចំនួន៣០គីឡូក្រាមដដែល ដោយបានប្រើឧបករណ៍ត្រាំស៊ីតឌ័រទេ។

**ជាលទ្ធផល** នៃការអនុវត្តន៍បច្ចេទេសផលិតកម្មដំណាំស្រូវ របស់គាត់យ៉ាងសកម្មគឺ ទទួលបានលទ្ធផលល្អមធ្យម ជាមួយនូវបទពិសោធន៍ និងជំនាញ ដែលទទួលបានទិន្នផលស្រូវនៅឆ្នាំ២០១៩ សរុបចំនួន០.៤២តោន ដោយទុកហូបចំនួន០.៣៩តោន និងទុកពូជចំនួន០.០៣តោន និងនៅឆ្នាំ២០២០ សរុបចំនួន០.៦តោន ដោយទុកពូជចំនួន០.០៣តោន និងលក់ចំនួន០.៥៧តោន ទទួលបានទឹកប្រាក់ចំនួន៥៧០,០០០រៀល។